ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

-លេខ: ...65...... "គ១"

ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២

-សំណុំរឿងរដ្ឋប្បវេណីលេខ ៨៩

ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងរាជធានីភ្នំពេញ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២ វេលាម៉ោង ០៩ និង ០០ នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ ៨៩ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០២១ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

### ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

ដើមចោទ៖ ឈ្មោះ [redacted] សុធារ៉ា ភេទស្រី អាយុ៣១ឆ្នាំ មុខរបរ កម្មករកាត់ដេរ មានទីលំនៅបច្ចុប្បន្ន[redacted]

អ្នកតំណាងដោយអាណត្តិ៖ មេធាវី [redacted] និងមេធាវី [redacted]។

ចុងចម្លើយ៖ ឈ្មោះ [redacted] ភាក់ ភេទប្រុស អាយុ៣៥ឆ្នាំ មុខរបរ កម្មករកាត់ដេរ មានទីលំនៅបច្ចុប្បន្ន[redacted]។

## I. អង្គហេតុ និងចំណុចវិវាទ

១-ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖

១-១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ភាក់។

១-២-សុំសិទ្ធិគ្រប់គ្រងកូនស្រីទាំងពីរនាក់ឈ្មោះ [redacted] ភីយ៉ាដា និងឈ្មោះ [redacted] ភីយ៉ានី។

១-៣-សុំសោហ៊ុយចាំបាច់ចិញ្ចឹមកូនផ្តាច់ចំនួន ១៥,០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

នៅក្នុងរឿងនេះ ដើមចោទឈ្មោះ [redacted] សុធារ៉ា និងចុងចម្លើយឈ្មោះ [redacted] ភាក់ ពិតជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០៥ ចុះថ្ងៃទី១៦-ឧសភា-២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ក្រោយពេលរៀបអាពាហ៍ពិពាហ៍រួចមក ដើមចោទ និងចុងចម្លើយរស់នៅមិនចុះសម្រុងរវាងគ្នា ទើបធ្វើឱ្យដើមចោទអស់មនោសញ្ចេតនារួមរស់ជាមួយគ្នាជាប្តីប្រពន្ធតទៅទៀត។ អំឡុងពេលរស់នៅជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយ បានបង្កើតកូន ០២នាក់ មានឈ្មោះ [redacted] ភីយ៉ាដា ភេទស្រី កើតថ្ងៃទី៣០-មេសា-២០០៦ និងឈ្មោះ [redacted] ភីយ៉ានី ភេទស្រី កើតថ្ងៃទី១៥-កុម្ភៈ-២០០៨។

៣-អង្គហេតុដែលអះអាងដោយដើមចោទ៖

-ឈ្មោះ [redacted] សុធារ៉ា បានអះអាងថា ខ្លួន និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមប្រពៃណី និងចុះសំបុត្រអាពាហ៍ពិពាហ៍កាលពីឆ្នាំ២០០៥ ហើយរហូតមកដល់ពេលបច្ចុប្បន្នមានកូនស្រីពីរនាក់ដែលមានឈ្មោះដូចខាងលើ។ ប៉ុន្តែក្នុងអំឡុងពេលមួយឆ្នាំចុងក្រោយនេះ ចំណងនិស្ស័យជាប្តីរបស់ពួកខ្លួនចាប់មានការរង្គោះរង្គើរ ដោយសារតែខ្លួនមានបញ្ហាសុខភាពមិនអាចផ្តត់ផ្គង់តម្រូវការផ្លូវភេទដល់ចុងចម្លើយបាន។ ហេតុដូចនេះហើយចុងចម្លើយចាប់ផ្តើមដើរ

លេងចោលផ្ទះដាច់យប់ និងលួចមានគូរកំណាន់លួចលាក់ផ្សេងទៀត ហើយមិនរវីរវល់ចិញ្ចឹមបីបាច់ថែរក្សាកូន និងផ្គត់ផ្គង់ជីវភាពដល់កូនៗដែលកំពុងសិក្សារៀនសូត្រ។ ដោយយល់ថាគ្មានសង្ឃឹម និងបន្តរួមរស់ជាប្តីប្រពន្ធឡើងវិញបាន ទើបខ្លួនសម្រេចចិត្តដាក់ពាក្យសុំមកតុលាការដើម្បីផ្តាច់ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់តែម្តង។

៤-អង្គហេតុដែលអះអាងដោយចុងចម្លើយ៖ ខ្លួនឯកភាពគ្រប់ចំណុចដែលដើមចោទបានលើកឡើង។

៥-ចំណុចគ្មានវិវាទ៖

-គូភាគីព្រមព្រៀងលែងលះគ្នា , ប្រគល់សិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ និងបង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនរួចហើយ។

៦-ចំណុចវិវាទ៖ គ្មាន។

## II.ការពិនិត្យភស្តុតាង

១-ភស្តុតាងជាឯកសាររបស់ដើមចោទ៖

-សំបុត្រអាពាហ៍ពិពាហ៍លេខ ០៥ ចុះថ្ងៃទី១៦-ឧសភា-២០០៥ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្រកំណើតលេខ ៤៥ ចុះថ្ងៃទី២២-ឧសភា-២០០៦ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្រកំណើតលេខ ១៨ ចុះថ្ងៃទី០៣-មីនា-២០០៨ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ៩១២ ចុះថ្ងៃទី០២-ធ្នូ-២០០៤ ចំនួន ០១ច្បាប់។ (ថតចម្លង)

-សំបុត្របញ្ជាក់កំណើតលេខ ១៣១៣ ចុះថ្ងៃទី២៣-មេសា-២០០៥ ចំនួន ០១ច្បាប់។ (ថតចម្លង)

-ពាក្យសុំពន្យារនីតិវិធីត្រៀម ចុះថ្ងៃទី១៩-កុម្ភៈ-២០២១ ចំនួន ០១ច្បាប់។

២-ភស្តុតាងជាឯកសាររបស់ចុងចម្លើយ៖ គ្មាន។

ក្រៅពីភស្តុតាងដែលភាគីបានដាក់ខាងលើ តុលាការពុំទទួលបានឯកសារផ្សេងនោះឡើយ។

៣-សាកសួរសាមីភាគី៖

-ដើមចោទឈ្មោះ [redacted] សុធារ៉ា បានឆ្លើយថា ខ្ញុំសុំលែងលះពីចុងចម្លើយ , សុំគ្រប់គ្រងកូន ០២នាក់ និងសុំទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូន ០២នាក់ មួយខែ ១០០$

-ចុងចម្លើយឈ្មោះ [redacted] ភាក់ បានឆ្លើយថា ខ្ញុំឯកភាពគ្រប់ការលើកឡើងរបស់ដើមចោទ។

## <u>សំអាងហេតុ</u>

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា៖

-ដើមចោទឈ្មោះ [redacted] សុធារ៉ា និងចុងចម្លើយឈ្មោះ [redacted] ភាក់ ពិតជាប្តីប្រពន្ធស្របច្បាប់ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ ០៥ ចុះថ្ងៃទី១៦-ឧសភា-២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់សំរោងក្រោម ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាភស្តុតាង។

-តាមកំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២ ឃើញថា ដើមចោទឈ្មោះ [redacted] សុធារ៉ា និងចុងចម្លើយឈ្មោះ ញ៉ឹន ភាក់ មានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងចំណងអាពាហ៍ពិពាហ៍ប្រាកដមែន ស្របតាមមាត្រា ៩៧៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

-អំឡុងពេលរស់នៅជាមួយគ្នាជាប្តី-ប្រពន្ធ ដើមចោទឈ្មោះ [redacted] សុធារ៉ា និងចុងចម្លើយឈ្មោះ [redacted] ភាក់ បង្កើតបានកូន០២នាក់ មានឈ្មោះ [redacted] គីយ៉ាដា ភេទស្រី កើតថ្ងៃទី៣០-មេសា-២០០៦ និងឈ្មោះ [redacted] គីយ៉ានី ភេទស្រី កើតថ្ងៃទី១៥-កុម្ភៈ-២០០៨ ហើយបានឯកភាពគ្នា កំណត់យកឈ្មោះ [redacted] សុធារ៉ា ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់នេះ និងឱ្យឈ្មោះ [redacted] ភាក់ បង់អាហារកាតព្វកិច្ចសម្រាប់ចិញ្ចឹមកូនទាំងពីរនាក់ ចំនួន ១០០$ ក្នុងមួយខែ។ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-ប្រាក់ប្រដាប់ក្តីគប្បីតុលាការសម្រេចតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។



Scanned with CamScanner

<u>សេចក្ដីសម្រេចបញ្ចប់</u>

១-ឱ្យឈ្មោះ [redacted]សុធារ៉ា និងឈ្មោះ[redacted] ភាក់ លែងលះពីគ្នាចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរតទៅ តាមមាត្រា ៩៧៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

២-កំណត់យកឈ្មោះ [redacted] សុធារ៉ា ជាអ្នកមានអំណាចមេបាលើកូន ០២នាក់ ដែលមានឈ្មោះ[redacted] ភីយ៉ាដា ភេទស្រី កើតថ្ងៃទី៣០-មេសា-២០០៦ និងឈ្មោះ[redacted] ភីយ៉ានី ភេទស្រី កើតថ្ងៃទី១៥-កុម្ភៈ-២០០៨ តាមការព្រមព្រៀងរបស់គូភាគី។ តាមមាត្រា ១០៣៧ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

ភាគីដែលពុំមានអំណាចមេបាលើកូន មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ហើយភាគីដែលមានអំណាចមេបាលើកូន ត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីដែលពុំមានអំណាចមេបា នៅពេលទៅសួរសុខទុក្ខកូន តាមមាត្រា ១០៤០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។

៣-ឱ្យឈ្មោះ[redacted]ភាក់ បង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរនាក់ ចំនួន ១០០$ ក្នុងមួយខែ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ឈ្មោះ [redacted]សុធារ៉ា។

សាលក្រមនេះបញ្ចប់ទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២ ចំពោះមុខដើមចោទ , ចំពោះមុខចុងចម្លើយ និងប្រកាសនៅថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា[redacted]

..........................................................................................................................................

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ សុក្រ ៤ រោច ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មករា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]